**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ : ០៩០៣/១៩ ក.អ.ជ

ថ្ងៃ ចន្ទ ១៥កើត ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៩

# របាយការណ៍
## វឌ្ឍនភាពការងារប្រចាំខែឧសភា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## I. សេចក្តីផ្តើម

ក្នុងខែឧសភា ឆ្នាំ២០១៩ ការងារអភិវឌ្ឍន៍ជនបទបាននឹងកំពុងបន្តបំពេញតួនាទីកាន់តែសកម្ម ក្នុងការបម្រើសេវាសាធារណៈទាំងផ្នែករឹង (Hardware) និងផ្នែកទន់ (Software) ដោយឈរលើមូលដ្ឋាន**ពង្រឹងគុណភាព និងគុណតម្លៃ** របស់ប្រជាជននៅជនបទ ។ កម្មវិធីចំនួន០៤ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ កំពុងលេចចេញជាផ្លែផ្កាឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦នេះហើយ ក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទរួមគ្នាជាមួយនឹងដៃគូ និងអង្គការក្រៅរដ្ឋាភិបាល កំពុងអនុវត្តកម្មវិធីពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទ ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និង អនាម័យជនបទ និងអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីជំរុញលើកកម្ពស់លក្ខខណ្ឌជីវិតរស់នៅរបស់ប្រជាជនឲ្យបានកាន់តែប្រសើរឡើង ។ លទ្ធផលក្នុងខែឧសភា ឆ្នាំ២០១៩ មានដូចខាងក្រោម៖

## II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែឧសភា ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១៨០៩នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែមេសា ឆ្នាំ២០១៩ មានការថយចុះចំនួន ០១នាក់ ដោយការផ្ទេរក្របខណ្ឌចេញ ។ ក្រសួងបានទទួលលិខិតចូលចំនួន ១២៣ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១៨០ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ០២៦ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២៧០ច្បាប់ ។

### ២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែឧសភា ឆ្នាំ ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិ សរុបចំនួន ២០ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០៤ ករណី ។

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

## ៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែឧសភា នេះ ក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៣ ៤៩០ ២៩៤ ១៧៥ រៀល ស្មើនឹង ២,៦៦% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ១២ ២៤៩ ៧២៤ ០០០ រៀល ស្មើនឹង ៦,៤៥% នៃច្បាប់ថវិកា ។

## ៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- បន្តកែសម្រួល និងបញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះត្រួតពិនិត្យការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តបាត់ដំបង និងខេត្តព្រះវិហារ
- ចុះពិនិត្យកែសម្រួលឡើងវិញ ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងការអនុវត្តផែនការឆ្នាំ២០១៩ របស់មន្ទីរនៅខេត្តពោធិ៍សាត់ និង ប៉ៃលិន
- ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យលើតារាងសំណួរអង្កេតនៅក្នុងកម្មវិធី CAPI និងលទ្ធផលនៃការធ្វើតេស្តសាកល្បងតារាងសំណួរអង្កេតចន្លោះជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ (CIAS) នៅទីស្តីការក្រសួងផែនការ
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់សំណើសុំអន្តរាគមន៍ដើម្បីនាំចូលរថយន្តថ្មីចំនួន ០១គ្រឿង ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ របស់អង្គការអភិវឌ្ឍន៍ធនធានអន្តរជាតិកម្ពុជា (RDI)
- បានចុះពិនិត្យការងាររបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងខេត្តបន្ទាយមានជ័យ និងពោធិ៍សាត់ ។

## ៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានចុះតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៩ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំនួន ០២ គឺ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់
- រៀបចំសិក្ខាសាលាពិនិត្យ និងកែសម្រួលឈ្មោះកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តសៀមរាបក្រោមអធិបតីភាព **ឯកឧត្តម សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំពិនិត្យប្រចាំឆ្នាំ២០១៨ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ក្រោមអធិបតីភាព **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ**

**អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(គ.ហ.ស.)

- ពិនិត្យ និងតាមដានការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០១៩ និងត្រៀមរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ២០២០ ( KPIs-2020 )
- ត្រៀមរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផែនការ និងហិរញ្ញវត្ថុ នៅខេត្តកំពត ។

### ៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ
- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០២ រួមមាន ខេត្តឧត្តរមានជ័យ និងសៀមរាប ។

## III. សកម្មភាពការងារជំនាញ

### ១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងស្ថាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន ៨២ គម្រោងកំពុងដំណើរការការដ្ឋានបានចំនួន ៤៧គម្រោង លទ្ធផលគិតជាមធ្យម ២៨.០០ %
- ការងារថែទាំខួប ប្រចាំ និងជួសជុលបន្ទាន់ឆ្នាំ២០១៩ កំពុងដំណើរការការដ្ឋាន
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព ០៧ គម្រោង អនុវត្តដោយនាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ នាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា និងជួសជុល ស្ថិតនៅ ខេត្តរតនគិរី កំពង់ចាម ព្រះវិហារ ពោធិ៍សាត់ ត្បូងឃ្មុំ និងកំពត លទ្ធផលវាយតម្លៃ ១០០%
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចរចារថ្លៃបានចំនួន ១២គម្រោង អនុវត្តដោយនាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ នៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ លើការងារស្ថាបនា ស្ថិតនៅក្នុងខេត្តកំពត សៀមរាប កំពង់ចាម កំពង់ឆ្នាំង ព្រៃវែង កណ្តាល បន្ទាយមានជ័យ កំពង់ស្ពឺ និងត្បូងឃ្មុំ
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព បានចំនួន ០២ខ្សែ ស្មើនិង ០២គម្រោង អនុវត្តដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។

### ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ខួងអណ្តូង បានចំនួន ០៣ អណ្តូង និងកំពុងបន្តខួងអណ្តូងទី៤ នៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
- ជួសជុលអណ្តូងស្នប់បានចំនួន ៥៤ អណ្តូងស្នប់ នៅខេត្តប៉ៃលិន កំពង់ចាម និងសៀមរាប

- ចុះត្រួតពិនិត្យ ការសាងសង់អណ្តូង ចំនួន ១១ អណ្តូង សម្រាប់ថវិកាកម្មវិធីឆ្នាំ ២០២០ នៅខេត្តកណ្តាល និងកំពង់ស្ពឺ
- បន្តការងារខួងអណ្តូងនៅសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម នៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ចំនួន ០២ អណ្តូង
- បានចូលរួម និងធ្វើជាវាគ្មិនបង្ហាញអំពីការផ្គត់ផ្គង់ទឹកស្អាតជនបទនៅកម្ពុជា ក្នុងសន្និសីទទឹកប្រចាំឆ្នាំ ស្តីពីការប្រែប្រួលអាកាសធាតុពិភពលោករបស់យើង នៅទីក្រុងមែលបិន ប្រទេសអូស្ត្រាលី
- បានចុះទស្សនកិច្ចសិក្សានៅកន្លែងស្ថានីយ៍បន្សុទ្ធ និងស្តុកទឹកទុក គម្រោងការយកពីទឹកប្រៃពីសមុទ្រ ដើម្បីបំលែងទៅជាទឹកសាបសម្រាប់ប្រើប្រាស់ "WATERSURE" នៅជាយទីក្រុងមែលបិន ប្រទេសអូស្ត្រាលី
- ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៣. ការងារថែទាំសុខភាព និងអនាម័យជនបទ

- សាងសង់បង្គន់អនាម័យចាក់ទឹកតាមផ្ទះឯកជន បានចំនួន ២៩៥ ខ្នងផ្ទះ នៅខេត្តពោធិ៍សាត់ និងឧត្តរមានជ័យ
- ចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំការលើក កម្ពស់អនាម័យសហគមន៍ នៅខេត្តចំនួន ០៦ រួមមាន ខេត្តឧត្តរមានជ័យ សៀមរាប កោះកុង ព្រះសីហនុ កែប និងត្បូងឃ្មុំ ដែលមានអ្នកចូលរួមសរុបចំនួន ៣១៩ នាក់ និងស្ត្រី ១០៨ នាក់
- ចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យនៅរាជធានីភ្នំពេញ ចំនួន ០៣ លើក ដែលមានប្រជាជនចូលរួមចំនួន ១៤៨ នាក់ កុមារចំនួន ៦៤ នាក់
- បានចូលរួមសហការជាមួយអង្គការ UNICEF បានបើកវគ្គតម្រង់ទិសអំពីគោលការណ៍នៅខេត្តស្វាយរៀង រយៈពេល០៤ថ្ងៃ មានការចូលរួមពីខេត្តគោលដៅ ទាំង០៦ខេត្ត រួមមាន ខេត្តព្រះវិហារ ក្រចេះ រតនគិរី កំពង់ស្ពឺ តាកែវ និងស្វាយរៀង ដោយអ្នកចូលរួមភាគច្រើនជាអភិបាលរងស្រុកគោលដៅ
- បានចូលរួមកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធស្តីអំពី ការផ្សព្វផ្សាយផែនការសកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនឈាម ដែលមានអ្នកជំនាញទាំងអស់មកពីស្ថាប័នជាតិ អន្តរជាតិ និងប្រធានមន្ទីរសុខាភិបាលទាំង២៥ រាជធានី-ខេត្ត នៅខេត្តកំពង់ចាម ។

## ៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះតាមដានការធ្វើបច្ចុប្បន្នភាព និងពិភាក្សាការងារពង្រឹងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
- ពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍ឆ្នាំ ២០១៩-២០២៣ លើសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកំពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារ នៅខេត្តព្រះសីហនុ និងកំពង់ឆ្នាំង

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបន្តវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ចំនួន ០៤ មុខជំនាញ ដែលមានសិក្ខាកាមសរុបចំនួន ១២១ នាក់ ស្រី ៥៥ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល នៅឃុំរាមអណ្តើក ស្រុកគីរីវង់ ។

៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ១៤០នាក់ ក្នុងនោះស្រីចំនួន ២៣នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៦២នាក់ ក្នុងនោះស្រីចំនួន ១១នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០៩នាក់ ក្នុងនោះស្រីចំនួន ០០នាក់
- មន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស ចំនួន ០១នាក់ ក្នុងនោះស្រីចំនួន ០០នាក់
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រី ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ក្នុងប្រទេស និងក្រៅប្រទេស ចំនួន ០២លើក
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងកម្មវិធីអាហារូបករណ៍ និងរៀបចំឯកសារសំណើជ្រើសរើសមន្ត្រី ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០២លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៩៦នាក់ ស្រី ៧២នាក់ លើ ០៤មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៥០នាក់ ស្រី ៦៥នាក់ លើ ០៧មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៦នាក់ ស្រី ៦៩នាក់ លើ ០២មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង និងបើកវគ្គរយៈពេលខ្លីសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១០៦នាក់ ស្រី ៥២នាក់ លើ ០៦មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧០នាក់ ស្រី ៥៣នាក់ លើ ០៣មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤៧នាក់ ស្រី ៣៤នាក់ លើ ០២មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានបន្តចុះផ្សព្វផ្សាយ ជ្រើសរើសទីតាំង និងបម្រុងឯកសារមេរៀនបន្ថែម លើ ០២មុខជំនាញ សម្រាប់គម្រោងបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបន្តផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនតាមវគ្គនីមួយៗ និងបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤៣នាក់ ស្រី ២៧នាក់ លើមុខវិជ្ជាភាសាអង់គ្លេស
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បន្តរៀបចំឯកសារមួយចំនួន និងបន្តការផ្សព្វផ្សាយពីគម្រោងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ ។

## ៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុប ចំនួន ៤ ៧១៧ ៩៧៧ ២៣៥ រៀល (បួនពាន់ប្រាំពីររយដប់ប្រាំពីរលានប្រាំបួនរយចិតសិបប្រាំពីរពាន់ពីររយសាមសិបប្រាំរៀល) ស្មើនឹង១ ១៩៨ ៧២០,២៧ ដុល្លារអាមេរិក (មួយលានមួយរយកៅសិបប្រាំបីពាន់ប្រាំពីររយម្ភៃដុល្លារនិងម្ភៃប្រាំពីរសេន)(១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៤៩០ នាក់នៅភូមិគោលដៅចំនួន ១៩៥ភូមិ ៧១ឃុំ ៣២ស្រុកក្នុងខេត្តគោលដៅចំនួន ១៥
- បានចុះបណ្តុះបណ្តាលបច្ចេកទេសការផលិតសាប៊ូលាងចាន ដល់ប្រជាជន នៅកំពង់ឆ្នាំង ចំនួន ០៣ វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៦៦នាក់ ស្រី ៥២នាក់
- បានចុះតាមដានគម្រោងតម្បាញហូល និងផលិតសាប៊ូលាងចាន ដល់ប្រជាជន នៅខេត្តតាកែវ
- បានចូលរួមប្រជុំការរៀបចំគម្រោងស្នើសុំថវិកាគាំទ្រពិសេសរបស់គណៈកម្មាធិការ មេគង្គ-ឡានឆាង នៅទីស្តីការក្រសួង
- បានចូលរួមប្រជុំជាមួយអ្នកជំនាញការចិន JPMU ពិនិត្យពីវឌ្ឍនភាពគម្រោងស្វាយអំពារ នៅទីស្តីការក្រសួង ។

## ៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមកិច្ចប្រជុំពេញអង្គ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច កាវែត ទំពួន និងព្រៅ ចំនួន ០៤សហគមន៍ នៅខេត្តស្ទឹងត្រែង និងរតនគិរី
- ចូលរួមសម្របសម្រួលកិច្ចប្រជុំពេញអង្គ ពិនិត្យ និងអនុម័តលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច គ្រឹង ចំនួន ០២សហគមន៍ នៅខេត្តរតនគិរី
- ចូលរួមប្រជុំជាមួយ អ្នកជំនាញរបស់អង្គការ ILO ដើម្បីពិភាក្សាការងារ លើការងារកែលម្អជីវភាពរស់នៅ និងលើកកម្ពស់គុណភាពជីវិត របស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង
- ចូលរួមពិធីផ្សព្វផ្សាយអំពី គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច និងដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចព័រ នៅខេត្តពោធិ៍សាត់ ។

៨. ការងារយេនឌ័រ

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០១៩-២០២៣ ក្រោមអធិបតីភាព **លោកជំទាវ ម៉ាត់ ម៉ារ៉ា** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារយេនឌរក្រសួងអភិវឌ្ឍន៍ជនបទនៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- រៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំតារាងផែនការថវិកា ឆ្នាំ២០១៩ សម្រាប់ការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់មុខងារនីមួយៗ
- បន្តរៀបចំមុខងារទាំង ០៣ ដែលត្រូវផ្ទេរដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## IV. **ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ**

១. គម្រោងកែលម្អផ្លូវជនបទ ដំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ ខែឧសភានេះគម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៤៤,៤៤%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៥៨,៥៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤៦,៣៨%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៤៨,៩៤%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៣១,៤៥%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៩៦,៩៣%

- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៩៦,៨៨%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៩២,៨១%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ ខែឧសភានេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ០៦%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ១០% ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទ ដោយត្រូវអនុវត្តជា ២ដំហាន ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គិតត្រឹមខែឧសភានេះ គម្រោងដែលបានស្នើសុំក្រាលគ្រួសក្រហមចំនួន ១៤១គម្រោង បាននិងកំពុងអនុវត្តការងារ បានចំនួន ១២៣គម្រោង ប្រវែង ៥៤៤ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ដំហាន ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០គម្រោង ប្រវែង ១៦១ ៤០៦ម៉ែត្រ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សាងសង់ថ្នាលហាលលាមកមានដំបូលថ្លាពេញ (Model1) នៅខេត្តបាត់ដំបង សម្រេចបាន ៨៥%
- សាងសង់ថ្នាលហាលលាមកមានដំបូលថ្លាពេញ (Model3) នៅខេត្តបាត់ដំបង សម្រេចបាន ៩៥%
- ការងារផ្គត់ផ្គង់សម្ភារបង្គន់គ្រួសារ បានដឹកចែកជូនប្រជាពលរដ្ឋ ខេត្តបន្ទាយមានជ័យបាន ១.៩៥៨ ខ្នងផ្ទះ (១០០%) ចំណែកប្រជាពលរដ្ឋជីក និងទំលាក់លូបង្គន់ក្នុងដីបាន ១៨៩៣ខ្នងផ្ទះ (៩៧%) ហើយប្រជាពលរដ្ឋបានធ្វើបង្គន់អនាម័យរួចរាល់បានចំនួន ១៨៩៣ខ្នងផ្ទះ (៩៧%)

- ជួសជុលស្រះសហគមន៍បាន ចំនួន ០១ នៅខេត្តពោធិ៍សាត់ស្មើនឹង ៩៥ % ។

## V. សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលខាងលើបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់សេវាសាធារណៈជនរួមមានផ្លូវថ្នល់ជនបទ សំណង់សិល្បការ្យផ្សេងៗ អណ្តូងទឹក ស្រះទឹកស្អាត បណ្តាញចែកចាយទឹកតាមទុយោនិងបង្គន់អនាម័យជនបទ ត្រូវបានក្រសួងយកចិត្តទុកដាក់អនុវត្តតាមផែនការឆ្នាំនីមួយៗ ដោយមានសូចនាករតាមដានផងដែរ ។ ការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាលអនាម័យ និងបរិស្ថានតាមសហគមន៍ កំពុងបង្កើតទម្លាប់រស់នៅក្នុងបរិយាកាសស្អាតតាមលំនៅឋានអ្នកស្រុក ដោយបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ។ ការបណ្តុះបណ្តាលជំនាញអាជីពមូលដ្ឋានបានរួមចំណែកបង្កើតការងារជាច្រើនដល់ប្រជាជន ជំរុញការផ្លាស់ប្តូរលក្ខខណ្ឌរស់នៅរបស់ប្រជាជនបានល្អប្រសើរ ដោយបានបង្កើនប្រាក់ចំណូលប្រចាំខែ ជានាជីវភាពរស់នៅសមរម្យក្នុងសង្គម ស្របនឹងចក្ខុវិស័យ ៥ឆ្នាំ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ៕

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**